ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការរកឃើញករណីថ្មី វិជ្ជមានវីរុសកូវីដ១៩ ជាជនជាតិខ្មែរ ០២ នាក់ នៅខេត្តសៀមរាប

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. សរុបស្ថានភាពជំងឺកូវីដ១៩ នៅទូទាំងប្រទេស៖**

គិតចាប់ពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ មកដល់ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២០ ស្ថានភាពជំងឺកូវីដ១៩នៅកម្ពុជា មានដូចតទៅ៖

- អ្នកព្យាបាលជាសះស្បើយសរុបចំនួន ២៣នាក់ (ស្មើនឹង ២១,១០ % ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ១៩ទាំងអស់) ដែលក្នុងចំនួននេះ មានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបារាំង ០១នាក់ និងបុរសជនជាតិខ្មែរ ១៨នាក់។
- អ្នកដែលកំពុងសម្រាកព្យាបាល សរុបចំនួន ៨៦នាក់ (ស្ត្រី ២៨នាក់ និងបុរស ៥៨នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេស សរុបចំនួន ១០៩នាក់ (ស្ត្រី ៣០នាក់ និងបុរស ៧៩នាក់)

**២. រកឃើញវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២ ករណីថ្មី នៅខេត្តសៀមរាប មានដូចតទៅ៖**

ស្ត្រីជនជាតិខ្មែរអាយុ ៣៩ឆ្នាំ និងកូនប្រុសអាយុ ១២ឆ្នាំ រស់នៅក្រុងសៀមរាប វិជ្ជមានវីរុសកូវីដ១៩។ ស្ត្រីរូបនេះ ជាភរិយាបុរសអាយុ ៥០ឆ្នាំ ដែលមានវីរុសកូវីដ១៩ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តសៀមរាប ហើយបុរសរូបនេះ ជាអ្នកដែលបានវិលត្រឡប់មកពីពិធីសាសនានៅប្រទេសម៉ាឡេស៊ី។ បុគ្គលទាំងពីរនាក់ (ម្តាយនិងកូន) ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តសៀមរាប។ រីឯកូន ០២នាក់ទៀត និងឪពុកក្មេក មានលទ្ធផលតេស្តអវិជ្ជមាន។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណី



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

កូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក ក្រុមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ០៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០